ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣✵៣

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០០៥ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០

លេខ: 452
ថ្ងៃទី 22-3-10 ម៉ោង 8

# សារាចរ

## ស្តីពី

## ការតម្លើងប្រាក់សោធនសម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ

ដោយអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រោមមាគាំដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កន្លងមកបានយកចិត្តទុកដាក់ តម្លើងប្រាក់សោធនជាបន្តបន្ទាប់ ដើម្បីជួយសម្រួលជីវភាពរស់នៅរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ បច្ចុប្បន្ន នេះ ត្រូវបានតម្លើងបន្តទៀតតាមអនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកែប្រែ តម្លៃឯកតានៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន និងការបង្កើនបៀវត្សរ៍សុទ្ធសាធរបស់មន្ត្រីរាជការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំដល់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ដូចតទៅ ៖

១ - ការគណនាប្រាក់សោធនរបស់និវត្តជន ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម ៖

| | | |
|---|---|---|
| ប្រាក់សោធនសរុបប្រចាំខែថ្មី | = | **ប្រាក់សោធនសុទ្ធសាធ** + ប្រាក់តម្លើងឱ្យស្មើបៀវត្សរ៍មូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមឱ្យស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងទៀត ប្រសិនបើមាន |
| **ប្រាក់សោធនសុទ្ធសាធ** | = | សន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន x ៨៧០ x អត្រាភាគរយប្រាក់សោធន |

២ - ការគណនាប្រាក់សោធនរបស់ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម ៖

| | | |
|---|---|---|
| ប្រាក់សោធនសរុបប្រចាំខែថ្មី | = | **ប្រាក់សោធនសុទ្ធសាធ** + ប្រាក់តម្លើងឱ្យស្មើ៥០% នៃបៀវត្សរ៍មូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមឱ្យស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងទៀត ប្រសិនបើមាន |
| **ប្រាក់សោធនសុទ្ធសាធ** | = | សន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន x ៨៧០ x អត្រាភាគរយប្រាក់សោធន |

៣ - ត្រូវរៀបចំសំណុំលិខិតស្នើសុំប្រាក់សោធនថ្មី ដូចខាងក្រោម ៖

- លិខិតស្នើសុំតម្លើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែចុងក្រោយ ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែថ្មី ០៣ ច្បាប់

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086